## ពាក្យពោលនាងសុជាតា

ខ្ញុំជានាងស្រីសុជាតា
ពេលមុនបានបន់ទេវតាអារក្សព្រៃ
ដោយន័យធ្លាប់ជឿជំនឿថា
អារក្សដើមព្រៃជាទេវតា
នាងបន់ប្រាថ្នាហេតុបីយ៉ាង
ហេតុមួយថាបើត្រូវមានប្ដី
ចិត្តអន្ត្តិរិយលាសំណាង
ប្រុសចិត្តអាក្រក់កុំជិតខាង
សូមលោកជួយនាងឱ្យផុតទុក្ខ
សូមឱ្យប្ដីនោះលុះដោយធម៌
មានចិត្តស្មោះសល្អបរិសុទ្ធ
ហេតុពីរថាសូមឱ្យបានបុត្រ
ដោយពិតចំហុតកូនប្រុសមុន
ហេតុបីសូមជួបតែអ្នកប្រាជ្ញ
ជាអ្នកអង់អាចស្គាល់ទោសគុណ
បើបានដូចចិត្តថ្វាយទានមុន
យកមកសងគុណលាបំណាន់
នាងសុជាតាបន់ទៅហើយ
មិនបានយូរឡើយនាងស្រីគន់
បានប្ដីចិត្តល្អដូចនាងបន់
បានកូនប្រុសមុនដូចចិត្តប៉ង
នាងជឿទេវតាអារក្សព្រៃ
នាងខំកែខៃពេកកន្លង
ធ្វើមធុបាយាសល្អហ្មត់ហ្មង
ប៉ុនប៉ងព្រឹកឡើងទូលទៅថ្វាយ
លាការបែបបន់បំណាន់នាង
ដើម្បីភស្តុតាងចិត្តស្រស់ស្រាយ
ដោយបានសម្រេចផលទាំងឡាយ
ដែលខ្លួនខ្វល់ខ្វាយពីមុនហោង
ទើបនាំទាសីទូលដង្វាយ
បាយាសទៅថ្វាយលាបំណាន់
ដល់ហើយនាងចូលដោយសង្វាត
ក្រាបទៀបព្រះបាទថ្វាយអភិវន្ទ
ទូលថាខ្ញុំសូមលាបំណាន់
ដែលបន់ពីមុនណាម្ចាស់ថ្លៃ។

## ពាក្យឆ្លើយតបរបស់ព្រះ

ព្រះអង្គទ្រង់ឆ្លើយតបថា
អាត្មាមិនមែនទេវតាអារក្សព្រៃ
ជាមនុស្សអ្នកបួសនៅក្នុងព្រៃ
រត់ភ័យក្លាចកើតចាស់ឈឺស្លាប់
រកធម៌ត្រាស់ដឹងជាព្រះពុទ្ធ
ឆ្លងសង្សារវដ្តឱ្យផុតចាប់
សម្ដែងទេសនាឱ្យសត្វស្ដាប់
ថ្លែងប្រាប់ទោសគុណអ្នករាល់គ្នា
បើនាងចង់ថ្វាយដល់អាត្មា
ចូរផ្គង់សច្ចាដោយសទ្ធា

កុំជឿអារក្សខ្មោចអ្នកតា ថាបន់ប្រាថ្នាបានដូចចិត្ត
បារមីដែលនាងសាងមកច្រើនជាតិ ផលនោះមិនឃ្លាតខុសគំនិត
និស្ស័យមានហើយចូរមកជិត ប្រគេនជីវិតតថាគត
មធុបាយាសដែលនាងថ្វាយ ដោះស្រាយអំពីបំណាន់ផុត
សទ្ធាជ្រះថ្លាដ៏មោះមុត ព្រះពុទ្ធទ្រង់ចាន់បានត្រាស់ចាប់។